**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ..៣៤៤៧១...អពដ

L202309260625TD2799

ថ្ងៃអង្គារ១២កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣

# សេចក្តីបំភ្លឺ

នាពេលថ្មីៗនេះ អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសង្កេតឃើញថា មានការលើកឡើងតាមបណ្តាញសង្គមមួយចំនួនដោយការភាន់ច្រឡំ ឬក្នុងចេតនាបំភាន់ មួលបង្កាច់ និងចោទប្រកាន់ដែលពុំបានឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែងចូលរួមចំណែកយ៉ាងសស្រាក់សស្រាំរបស់អគ្គនាយកដ្ឋានពន្ធដារក្នុងការអនុវត្តតួនាទីភារកិច្ចក្នុងការងារគ្រប់គ្រងប្រមូលចំណូលពន្ធស្របតាមច្បាប់ស្តីពីសារពើពន្ធ ក៏ដូចជាមកលើរាជរដ្ឋាភិបាលនីតិកាលថ្មីដែលមាន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាប្រមុខដឹកនាំ។ ដើម្បីចៀសវាងការភាន់ច្រឡំដោយប្រការណាមួយមកលើកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច កែលម្អបរិយាកាសធុរកិច្ច និងលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ ក៏ដូចជាកិច្ចខិតខំប្រឹងប្រែងក្នុងការបន្តកែទម្រង់រដ្ឋបាលសារពើពន្ធ អគ្គនាយកដ្ឋានពន្ធដារសូមបំភ្លឺជូនសាធារណជន ដូចតទៅ៖

## ១. អំពីការយកពន្ធលើចំណេញមូលធន

ពន្ធលើចំណេញមូលធន គឺមិនមែនជាប្រភេទពន្ធដែលទើបតែបង្កើតថ្មីនោះទេ។ សម្រាប់នីតិបុគ្គល ពន្ធនេះត្រូវបានដាក់ឱ្យអនុវត្តចាប់តាំងពីឆ្នាំ១៩៩៤ មកម្ល៉េះ។ ជាក់ស្តែង ក្រុមហ៊ុន និងសហគ្រាសនានាបានបង់ពន្ធលើប្រាក់ចំណូលដែលរួមបញ្ចូលទាំងចំណេញមូលធន មិនតែប៉ុណ្ណោះសហគ្រាសដែលប្រកបអាជីវកម្មលើវិស័យអចលនទ្រព្យក៏បានបង់ពន្ធនេះដែរ។ ក្រោយមក ពន្ធលើចំណេញមូលធនត្រូវបានដាក់បញ្ចូលក្នុងច្បាប់ស្តីពីសារពន្ធឆ្នាំ១៩៩៧ ហើយការអនុវត្តពន្ធលើចំណេញមូលធនសម្រាប់រូបវន្តបុគ្គលត្រូវបានចែងលម្អិតក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៧។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំលិខិតបទដ្ឋានគតិយុត្ត បែបបទ និងនីតិវិធីនៃការប្រមូលពន្ធលើចំណេញមូលធនសម្រាប់រូបវន្តបុគ្គលរួចរាល់តាំងពីឆ្នាំ២០២០ ដោយផ្អែកលើគោលការណ៍ទន់ភ្លន់ សាមញ្ញ ជាមួយនឹងការអនុគ្រោះក្នុងកម្រិតខ្ពស់ ប្រសិនបើធៀបនឹងការអនុវត្តនៅបណ្តាប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍ក្នុងតំបន់និងសាកលលោក។ ជាការគិតគូរចំពោះផលប៉ះពាល់នានាបណ្តាលពីការរីករាលដាលនៃជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ក៏បានសម្រេចពន្យារពេលអនុវត្តពន្ធលើចំណេញមូលធនសម្រាប់រូបវន្តបុគ្គល ជាបន្តបន្ទាប់ចំនួន ៣ លើករួចមកហើយ ដោយចុងក្រោយកំណត់យករយៈពេលអនុវត្ត ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ សម្រាប់ទ្រព្យជាមូលធន ៥ផ្នែក (ភតិសន្យា, ទ្រព្យវិនិយោគ, កេរ្តិ៍ឈ្មោះអាជីវកម្ម, កម្មសិទ្ធិបញ្ញា និងរូបិយវត្ថុបរទេស)។ ដោយឡែក ពន្ធលើចំណេញមូលធនសម្រាប់ផ្នែកអចលនទ្រព្យ រាជរដ្ឋាភិបាលបានសម្រេចពន្យារការចាប់ផ្តើមអនុវត្តរហូតដល់ដំណាច់ឆ្នាំ២០២៤ ដើម្បីជាចំណែកដ៏សំខាន់មួយចូលរួមគាំទ្របន្ថែមដល់វិស័យអចលនទ្រព្យ។

ដូច្នេះ ការលើកឡើងថា រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ដែលដឹកនាំដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** បានបង្កើតពន្ធថ្មី ឬដំឡើងអត្រាពន្ធ គឺពុំឆ្លុះបញ្ចាំងពីការពិតនោះទេ។ **ផ្ទុយទៅវិញ រាជរដ្ឋាភិបាលបាននិងកំពុងពិចារណាបន្ថែមលើក្របខ័ណ្ឌក្នុងការសម្រួលការអនុវត្តពន្ធលើចំណេញមូលធន ក៏ដូចជា រយៈពេលកំណត់សមស្របក្នុងការចាប់ផ្តើមអនុវត្តពន្ធលើចំណេញមូលធនសម្រាប់រូបវន្តបុគ្គលនេះ។**



អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

L202309260625TD2799

## ២. ការលើកឡើងជារួមពាក់ព័ន្ធនឹងពន្ធដារ

ចំពោះការលើកឡើងនៅតាមបណ្តាញសង្គមមួយចំនួន គឺពុំបានឆ្លុះបញ្ចាំងពីភាពត្រឹមត្រូវនោះទេ ពោលគឺមានចេតនាបំភាន់ មួលបង្កាច់ និងចោទប្រកាន់មកលើអគ្គនាយកដ្ឋានពន្ធដារដែលជាស្ថាប័នរាជរដ្ឋាភិបាល ដែលកន្លងមកបានខិតខំប្រឹងប្រែងចូលរួមចំណែកយ៉ាងសកម្មក្នុងការអនុវត្តតួនាទីភារកិច្ច ក៏ដូចជាមកលើរាជរដ្ឋាភិបាលនីតិកាលថ្មីដែលមាន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ជាប្រមុខដឹកនាំ ដែលបាននិងកំពុងខិតខំយ៉ាងសស្រាក់សស្រាំក្នុងការដឹកនាំនាវាកម្ពុជាបន្តស្ថិតលើមាគ៌ាដ៏ត្រឹមត្រូវ ប្រកបដោយស្ថិរភាព និងសុខសន្តិភាព ជាពិសេស ការខិតខំខ្នះខ្នែងទាក់ទាញវិនិយោគក្នុងស្រុកនិងបរទេស ទន្ទឹមនឹងការពិចារណាគិតគូរជាបន្តបន្ទាប់លើសុខទុក្ខ និងលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ។

ក្នុងន័យបំភ្លឺបន្ថែមនិងចៀសវាងការភាន់ច្រឡំពីមតិសាធារណជនទូទៅ អគ្គនាយកដ្ឋានពន្ធដារសូមបំភ្លឺចំពោះចំណុចមួយចំនួនដូចខាងក្រោម៖

### ក. ការលើកឡើងថា "រដ្ឋគិតតែយកពន្ធ ខណៈដែលប្រទេសផ្សេងកាត់បន្ថយពន្ធ ឬដាក់ចេញវិធានការលើកទឹកចិត្ត"

ឆ្លើយតបនឹងការលើកឡើងនេះ អគ្គនាយកដ្ឋានពន្ធដារសូមជម្រាបជូនថា ទន្ទឹមនឹងការប្រមូលចំណូលដើម្បីការអភិវឌ្ឍសង្គមជាតិ ធានាតម្លាភាព និងការប្រកួតប្រជែងដោយស្មើភាព រាជរដ្ឋាភិបាលក៏បានគិតគូរខ្ពស់ពីការសម្រួលបរិយាកាសវិនិយោគ ក៏ដូចជាការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដោយបានដាក់ចេញនូវវិធានការលើកទឹកចិត្តជាច្រើនជាបន្តបន្ទាប់និងស្ទើរគ្រប់វិស័យ។ ក្នុងនោះ ការដាក់ចេញនូវវិធានការលើកទឹកចិត្តផ្នែកសារពើពន្ធដើម្បីសម្រួលដល់ជីវភាពប្រជាពលរដ្ឋទូទៅ ជាអាទិ៍មាន៖

- ការលុបចោលរបបពន្ធម៉ៅការ និងអាករលើផលរបរ ដើម្បីបញ្ចប់នូវបញ្ហាស្មុគស្មាញរបស់ប្រជាពលរដ្ឋដែលប្រកបអាជីវកម្មតូចតាចគ្រាន់តែដើម្បីចិញ្ចឹមជីវិត និងជាការលុបបំបាត់កន្លែងលាក់ខ្លួនរបស់អ្នកជាប់ពន្ធដែលត្រូវបញ្ចូលក្នុងរបបស្វ័យប្រកាស
- កំណត់បន្ថែមការផ្គត់ផ្គង់មួយចំនួនជាការផ្គត់ផ្គង់មិនជាប់អាករលើតម្លៃបន្ថែម រួមមាន សេវាសិក្សាអប់រំ, ថាមពលអគ្គិសនីនិងទឹកស្អាតជូនប្រជាពលរដ្ឋប្រើប្រាស់, ផលិតផលកសិកម្មមិនទាន់កែច្នៃ និងសេវាប្រមូលសំរាម យន្តការនេះមានគោលបំណងដើម្បីលើកកម្ពស់ជីវភាពរស់នៅនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ការសម្រួលកម្រិតប្រាក់ពន្ធប៉ាតង់ដែលត្រូវបង់ដើម្បីជាការលើកទឹកចិត្តសហគ្រាសតូចៗក្នុងការប្រកបអាជីវកម្ម
- ការលុបចោលពន្ធសត្តឃាតដើម្បីជួយកាត់បន្ថយបន្ទុកចំណាយលើសាច់សត្វដែលជាអាហារមូលដ្ឋានសម្រាប់ចិញ្ចឹមជីវិត ក៏ដូចជាជួយសម្រាលជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋបានមួយកម្រិតថែមទៀត
- ការដាក់ចេញនូវវិធានគណនេយ្យសាមញ្ញ ដើម្បីជួយសម្រួលដល់អ្នកជាប់ពន្ធតូចក្នុងកិច្ចប្រតិបត្តិការអាជីវកម្មតូចៗ ឬអាជីវកម្មដែលមានលក្ខណៈគ្រួសារ
- ការកាត់បន្ថយជាច្រើនលើកនូវមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស តាមរយៈការដំឡើងជាបន្តបន្ទាប់នូវកម្រិតអប្បបរមានៃប្រាក់បៀវត្សត្រូវជាប់ពន្ធ និងភាគនៃប្រាក់ចំណូលដែលត្រូវជាប់ពន្ធលើប្រាក់ចំណូល ដើម្បីធានាថាមន្ត្រីរាជការសាធារណៈនិងកម្មករ-និយោជិត ដែលទទួលបានប្រាក់បៀវត្សឬប្រាក់ឈ្នួលអប្បបរមាមិនត្រូវជាប់ពន្ធលើប្រាក់បៀវត្សឡើយ
- ការលុបការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនចំពោះយានយន្តមួយចំនួន ជាអាទិ៍ ទោចក្រយានយន្ត, ត្រីចក្រយានយន្ត, ជលយានយន្ត, ត្រាក់ទ័រ និងគ្រឿងយន្តប្រហាក់ប្រហែលមួយចំនួន ដើម្បីសម្រាលបន្ទុកចំណាយរបស់ប្រជាពលរដ្ឋទូទៅ
- ការអនុគ្រោះពន្ធប្រថាប់ត្រាចំពោះការទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យក្នុងរង្វង់ញាតិ
- ការលុបចោលពន្ធប្រថាប់ត្រាលើលិខិតគតិយុត្តស្តីពីការបង្កើតក្រុមហ៊ុន

L202309260625TD2799

- ការកែសម្រួលពន្ធតែមប្រិ៍ ដោយលើកលែងការអនុវត្តចំពោះលិខិតគតិយុត្តមួយចំនួន ជាអាទិ៍ លិខិតស្នើសុំពាក់ព័ន្ធនឹងវិស័យអប់រំ, ស្នើសុំចូលបម្រើការងារ, សំបុត្រអគ្រានុកូលដ្ឋាន។ល។ និង
- ការកែសម្រួលអត្រាការប្រាក់ប្រចាំខែចំពោះពិន័យពីការកំណត់ពន្ធឡើងវិញនិងការបង់ពន្ធយឺតយ៉ាវនៃប្រាក់ពន្ធដែលបង់ខ្វះ ដើម្បីសម្រួលអត្រាការប្រាក់តាមស្ថានភាពទីផ្សារជាក់ស្តែង, បន្ធូរបន្ថយបន្ទុករបស់វិស័យឯកជន និងសម្រួលកិច្ចពាណិជ្ជកម្ម។

បន្ថែមពីនេះ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវវិធានការលើកទឹកចិត្តផ្នែកពន្ធដារជាច្រើនទៀតតាមវិស័យសំខាន់ៗ ក្នុងនោះមានជាអាទិ៍៖

- **គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ (QIP)**
    - ការអនុគ្រោះពន្ធចំពោះគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ (QIP) ជាពិសេស លើកលែងពន្ធលើប្រាក់ចំណូល សម្រាប់រយៈពេលចាប់ពី ៣ឆ្នាំ រហូតដល់ ៩ឆ្នាំ និងការលើកទឹកចិត្តឱ្យបង់ពន្ធលើប្រាក់ចំណូលតាមអត្រាកំណើន ត្រឹមកម្រិត ២៥%, ៥០%, និង ៧៥% សម្រាប់រយៈពេល ២ ឆ្នាំជាបន្តបន្ទាប់ បន្ទាប់ពីផុតរយៈពេលលើកលែងពន្ធ
    - ការអនុគ្រោះការអនុវត្តអាករលើតម្លៃបន្ថែម (VAT) សម្រាប់ឧស្សាហកម្មគាំទ្រ ឬអ្នកចុះកិច្ចសន្យាធ្វើការផ្គត់ផ្គង់ទំនិញឬសេវាដោយផ្ទាល់ សម្រាប់បម្រើឱ្យការនាំចេញរបស់ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មផលិតស្បែកជើង ឧស្សាហកម្មផលិតកាបូបយួរនិងកាបូបដៃ និងឧស្សាហកម្មផលិតមួក
    - វិធានការលើកទឹកចិត្តផ្នែកពន្ធដារដល់សកម្មភាព កាត់ ដេរ និងតម្រឹម របស់គម្រោងវិនិយោគមានលក្ខណ-សម្បត្តិគ្រប់គ្រាន់ (QIP)
    - ការអនុគ្រោះឱ្យព្យួរទុកជាបណ្តោះអាសន្ននូវការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលរបស់សហគ្រាសឧស្សាហកម្មផ្នែកវាយនភ័ណ្ឌកាត់ដេរ
- **វិស័យមូលបត្រ**
    - វិធានការលើកទឹកចិត្តផ្នែកពន្ធដល់វិស័យមូលបត្រ ជាពិសេសការលើកលែងពន្ធលើប្រាក់ចំណូលចំនួន ៥០% នៃពន្ធលើប្រាក់ចំណូលត្រូវបង់សរុបសម្រាប់រយៈពេល ៣ឆ្នាំ, ការអនុគ្រោះបំណុលពន្ធ, និងការបន្ថយពន្ធកាត់ទុក ៥០% ការប្រាក់ និងភាគលាភ បានមកពីការកាន់កាប់និងទិញ-លក់មូលបត្រ
- **វិស័យហិរញ្ញវត្ថុ**
    - ការព្យួរទុកជាបណ្តោះអាសន្ននូវការអនុវត្ត អាករលើតម្លៃបន្ថែម (VAT) លើសេវាដែលមិនមែនជាមូលដ្ឋានខាងហិរញ្ញវត្ថុ
    - ការអនុគ្រោះពន្ធកាត់ទុកលើការទូទាត់ការប្រាក់លើប្រាក់កម្ចីពីបរទេសរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- **វិស័យកសិកម្ម**
    - ការលើកទឹកចិត្តពន្ធបន្ថែមចំពោះការដាំដុះស្រូវ ការប្រមូលទិញស្រូវ និងការផលិតអង្ករនាំចេញ
    - ការចាត់ទុកជាបន្ទុករបស់រដ្ឋនូវអាករលើតម្លៃបន្ថែមលើការនាំចូលនិងផ្គត់ផ្គង់ទំនិញក្នុងវិស័យកសិកម្ម
    - ការអនុគ្រោះអាករលើតម្លៃបន្ថែមចំពោះអ្នកចុះកិច្ចសន្យាផ្គត់ផ្គង់អង្ករសម្រាប់បម្រើការនាំចេញអង្ករ
    - ការលើកទឹកចិត្តផ្នែកពន្ធដារដល់សហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យអាទិភាព (ផលិតផលកសិកម្ម ឬកសិ-ឧស្សាហកម្ម)
    - ការលើកទឹកចិត្តពន្ធដារចំពោះការផ្គត់ផ្គង់ផលិតផលកសិកម្មមិនទាន់កែច្នៃ
    - ការព្យួរប្រាក់រំដោះពន្ធលើប្រាក់ចំណូល ចំពោះវិស័យកសិកម្ម (ផលិតផលកសិកម្មដែលត្រូវទទួលបានការអនុគ្រោះរួមមាន ស្រូវ អង្ករ ពោត សណ្តែក ម្រេច គ្រាប់ស្វាយចន្ទី ដំឡូងមី និងកៅស៊ូ)
    - ការលើកទឹកចិត្តផ្នែកពន្ធដារចំពោះសហគ្រាសផលិត ផ្គត់ផ្គង់ក្នុងស្រុក ឬនាំចេញស្រូវ អង្ករ ពោត សណ្តែក ម្រេច ដំឡូងមី គ្រាប់ស្វាយចន្ទី និងជ័រកៅស៊ូ

L202309260625TD2799

- **វិស័យអប់រំ**
  - ការលើកលែងពន្ធដារសម្រាប់គ្រឹះស្ថានសិក្សា ដោយលើកលែងពន្ធលើប្រាក់ចំណូល រួមទាំងប្រាក់រំដោះពន្ធលើប្រាក់ចំណូលនិងពន្ធអប្បបរមា, អាករលើតម្លៃបន្ថែម, និងពន្ធកាត់ទុកលើសេវា ការប្រាក់ និងភាគលាភ រហូតដល់ឆ្នាំ២០២៨
- **វិស័យទេសចរណ៍**
  - ការលើកលែងការអនុវត្តកាតព្វកិច្ចពន្ធដារសម្រាប់ភ្នាក់ងារទេសចរណ៍ និងការីទេសចរណ៍
- **វិស័យសំណង់**
  - ការអនុញ្ញាតឱ្យសហគ្រាសសំណង់បង់ប្រាក់ពន្ធតាមការគណនាជាក់ស្ដែងនៃគម្រោងនីមួយៗជាមុន
  - វិធានការគាំទ្រដល់ការអភិវឌ្ឍវិស័យសំណង់ និងអចលនទ្រព្យផ្នែកបុរី
- **វិស័យអចលនទ្រព្យ**
  - ការលើកលែងពន្ធលើអចលនទ្រព្យ ចំពោះអចលនទ្រព្យស្ថិតក្នុងភូមិសាស្ត្រមួយចំនួន
  - ការលើកទឹកចិត្តចំពោះវិស័យអចលនទ្រព្យ ជាពិសេស ការលើកលែងពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់លំនៅដ្ឋានគ្រប់ប្រភេទ ដែលមានតម្លៃក្រោម ឬស្មើ ៧ ម៉ឺនដុល្លារ និងការបង្កើនរយៈពេលបង់ពន្ធជាកញ្ចប់សម្រាប់ក្រុមហ៊ុនអ្នកអភិវឌ្ឍន៍លំនៅឋាន
- **ការលើកទឹកចិត្តផ្នែកពន្ធដារចំពោះវិស័យសំខាន់ៗជាច្រើនទៀត**
- **បន្ថែមពីនេះ កាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ កន្លងទៅ រាជរដ្ឋាភិបាលបានអនុម័តលើយុទ្ធសាស្ត្រជាតិស្ដីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឆ្នាំ២០២៣-២០២៨ ដែលរួមបញ្ចូលវិធានការសម្រួលខាងសារពើពន្ធមួយចំនួនទៀត ដើម្បីគាំទ្រដល់សេដ្ឋកិច្ចក្រៅប្រព័ន្ធដែលអគ្គនាយកដ្ឋានពន្ធដារកំពុងរៀបចំលិខិតបទដ្ឋានគតិយុត្តចាំបាច់នានាក្នុងការជំរុញការអនុវត្ត។**

## ខ. ការលើកឡើងអមដោយរូបភាពឬព្រឹត្តិការណ៍ចាស់ៗដែលជាការភាន់ច្រឡំកើតឡើងយូរមកហើយនិងត្រូវបានបកស្រាយបំភ្លឺច ឬព័ត៌មានមិនត្រឹមត្រូវ មកបំភាន់បំផុសបំផុលសាធារណជន

អគ្គនាយកដ្ឋានពន្ធដារក៏បានកត់សម្គាល់ឃើញថា ស្ថិតក្នុងស្ថានភាពដែលសាធារណជនមួយចំនួនមានការភាន់ច្រឡំអំពីការអនុវត្តពន្ធលើចំណេញមូលធន និងវិធានការប្រមូលចំណូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ មានការលើកឡើងមួយចំនួនបានប្រើប្រាស់រូបភាពឬព្រឹត្តិការណ៍ចាស់ៗដែលធ្លាប់មានការភាន់ច្រឡំនិងបានបកស្រាយបំភ្លឺចជាយូរមកហើយ ឬព័ត៌មានមិនត្រឹមត្រូវ មកប្រើប្រាស់ដើម្បីបំផុសបំផុលក្នុងចេតនាទាញយកផលប្រយោជន៍ផ្ទាល់ខ្លួន ឬអូសទាញអ្នកទស្សនា ដែលបង្កឱ្យមានការភាន់ច្រឡំមកលើអគ្គនាយកដ្ឋានពន្ធដារ ក៏ដូចជា រាជរដ្ឋាភិបាល។

ក្នុងន័យនេះ អគ្គនាយកដ្ឋានពន្ធដារសូមអំពាវនាវដល់សាធារណជនទូទៅ សូមចៀសវាងនូវការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានទាំងឡាយណាដែលមិនមែនជាការពិត ឬមិនច្បាស់លាស់ក្នុងចេតនាបំភាន់និងមួលបង្កាច់រាជរដ្ឋាភិបាល ឬធ្វើឱ្យមានការភាន់ច្រឡំណាមួយដល់សាធារណជន។

## គ. ការលើកឡើងថាមានការអនុវត្តការប្រមូលពន្ធ ១% ពីអ្នកខ្ចីលុយពីធនាគារ

មានការលើកឡើងថាមានការអនុវត្តការប្រមូលពន្ធ ១% ពីអ្នកខ្ចីលុយពីធនាគារ ដែលនេះជាការលើកឡើងមិនត្រឹមត្រូវនោះទេ ហើយអគ្គនាយកដ្ឋានពន្ធដារសូមបំភ្លឺបញ្ជាក់ថា យោងតាមច្បាប់ស្ដីពីសារពើពន្ធជាធរមាន ពុំមានការកំណត់ណាមួយតម្រូវឱ្យយកពន្ធ ១% លើប្រាក់កម្ចីរបស់ប្រជាពលរដ្ឋនោះទេ។

L202309260625TD2799

**ឃ. ការលើកឡើងថាមានការដំឡើងពន្ធព្រលានយន្តហោះ ចំពោះអ្នកដំណើរនិងភ្ញៀវទេសចរណ៍**

មានការលើកឡើងថាមានការប្រមូលពន្ធឬដំឡើងពន្ធព្រលានយន្តហោះទៅក្រៅប្រទេស ឬពន្ធសំបុត្រយន្តហោះ ដែលករណីនេះគឺជាការលើកឡើងពុំឆ្លុះបញ្ចាំងពីការពិតនោះទេ ហើយច្បាប់ស្តីពីសារពើពន្ធជាធរមានក៏ពុំមានចែង អំពីប្រភេទពន្ធលើព្រលានយន្តហោះនោះឡើយ។ ការលើកឡើងនេះអាចជាការលើកឡើងសំដៅដល់ការស្នើដំឡើង កម្រៃសេវាកម្មអ្នកដំណើររបស់ក្រុមហ៊ុនឯកជនដែលអភិវឌ្ឍនិងគ្រប់គ្រងអាកាសយានដ្ឋាន។

**ង. ការលើកឡើងអំពីការធ្លាក់ថ្លៃនៃផលិតផលកសិកម្មបណ្តាលមកពីការយកពន្ធ**

ករណីនេះ អគ្គនាយកដ្ឋានពន្ធដារសូមបំភ្លឺជូនសាធារណជនជ្រាបថា កន្លងមករាជរដ្ឋាភិបាលតែងតែមានការ គិតគូរនិងយកចិត្តទុកដាក់ខ្ពស់ ព្រមទាំងចាត់ទុកវិស័យកសិកម្មគឺជាវិស័យអាទិភាព។ តាមរយៈនេះ រាជរដ្ឋាភិបាលបាន ដាក់ចេញជាបន្តបន្ទាប់នូវវិធានការលើកទឹកចិត្តលើផ្នែកផ្សេងៗ និងជាពិសេសបានផ្តល់ការលើកទឹកចិត្តផ្នែកពន្ធដារ ចំពោះវិស័យកសិកម្មទាំងស្រុងដូចបានជម្រាបជូនក្នុងចំណុចទី២-ក។ ដូច្នេះ ការលើកឡើងថាការធ្លាក់ថ្លៃនៃផលិតផល កសិកម្មបណ្តាលមកពីការយកពន្ធ ពុំឆ្លុះបញ្ចាំងពីការពិតនិងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការជួយជ្រោមជ្រែង វិស័យកសិកម្មឡើយ។

ជារួម តាមរយៈការសង្កេតលម្អិតលើករណីនីមួយៗដែលត្រូវបានលើកឡើង អគ្គនាយកដ្ឋានពន្ធដារពិនិត្យឃើញ ថាក្នុងចំណោមការលើកឡើងទាំងនោះ មួយចំនួនលើកឡើងក្នុងន័យបង្កាច់បង្ខូចកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល នីតិកាលថ្មីពីសំណាក់ក្រុមប្រឆាំង, មួយចំនួនផ្សព្វផ្សាយក្រោមចេតនាធ្វើឱ្យមានការភាន់ច្រឡំដើម្បីប្រយោជន៍ផ្ទាល់ខ្លួន, មួយចំនួនលើកឡើងដោយការភាន់ច្រឡំហើយផ្សព្វផ្សាយបន្តគ្នា និងមួយចំនួនទៀតលើកឡើងក្នុងគោលដៅទាក់ទាញ អ្នកទស្សនា។ អគ្គនាយកដ្ឋានពន្ធដារក៏សូមថ្លែងអំណរគុណចំពោះការលើកឡើងមួយចំនួនដែលមានការស្វែងយល់បាន ច្រើនអំពីពន្ធ ដោយបានលើកឡើងជួយពន្យល់បកស្រាយជូនប្រជាពលរដ្ឋឱ្យមានការយល់ដឹងបន្ថែម ចៀសវាងការ ភាន់ច្រឡំនានាមកលើរាជរដ្ឋាភិបាល។

ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋានពន្ធដារសូមជម្រាបជូនសាធារណជនជ្រាបថា កន្លងមក អគ្គនាយកដ្ឋានពន្ធដារ នៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តែងប្រកាន់ខ្ជាប់នូវគោលការណ៍ពង្រឹងអភិបាលកិច្ចល្អ និងជាស្ថាប័នរាជរដ្ឋាភិបាលមួយ ក្នុងចំណោមស្ថាប័នដែលឈានមុខក្នុងការកែទម្រង់ ជាពិសេសការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ និងទទួលបាន លទ្ធផលយ៉ាងល្អប្រសើរនាពេលកន្លងមក។

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមអំពាវនាវនិងលើកទឹកចិត្តដល់សាធារណជន ទាំងអស់សូមធ្វើការឈ្វេងយល់ពីព័ត៌មានដែលត្រូវបានផ្សព្វផ្សាយជាសាធារណៈ ចៀសវាងទទួលបាននិងចែករំលែក បន្តនូវព័ត៌មានបំភាន់ ក្លែងបន្លំ និងនាំឱ្យសាធារណជនមានការយល់ច្រឡំ។ ក្នុងករណីមានចម្ងល់នានាពាក់ព័ន្ធនឹង ពន្ធដារ សូមធ្វើការទាក់ទងមកមជ្ឈមណ្ឌលពិគ្រោះយោបល់ (Call center) តាមរយៈលេខទូរស័ព្ទ ១២៧៧ ដោយ ឥតគិតថ្លៃ រៀងរាល់ម៉ោងធ្វើការ ឬកម្មវិធីជជែកផ្ទាល់ជាមួយពន្ធដារ GDT Live Chat។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់ ជ្រាបជាព័ត៌មាន។

**អគ្គនាយកដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋាន ពន្ធដារ